## ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៨៣ ចុះថ្ងៃទី០២/០៣/២០០៩ ស្តីពីការកែសម្រួលមាត្រា ១៣ និងមាត្រា ៣០ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា និងការកែសម្រួលមាត្រា ១១ថ្មី នៃព្រះរាជក្រឹត្យស្តីពីការកែសម្រួលមាត្រា ១០ មាត្រា១១ មាត្រា ១៤ មាត្រា ១៥ និងមាត្រា ១៦ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានយល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ស្តីពីការកែសម្រួលមាត្រា ១០ មាត្រា១១ មាត្រា១៤ មាត្រា ១៥ និងមាត្រា ១៦នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តិ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

### មាត្រា មួយ.

មាត្រា ១៣ និងមាត្រា ៣០ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ត្រូវបានកែសម្រួល ដូចខាងក្រោម ៖

### មាត្រា ១៣ថ្មី

សមាជិក **គ.ទ.ក** មានអាណត្តិបីឆ្នាំ ហើយអាចត្រូវជ្រើសតាំងបន្តរយៈពេលបីឆ្នាំទៀតបាន តាមរយៈការតែងតាំង ឬតាមរយៈការបោះឆ្នោត ដែលអនុវត្តតាមនីតិវិធីកំណត់ក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា ១០ មាត្រា ១១ មាត្រា១៤ មាត្រា ១៥ និងមាត្រា ១៦ នៃព្រះរាជក្រឹត្យ ស្តីពីការទទួលគុណភាពអប់រំឧត្តមសិក្សា ។

### មាត្រា ៣០ថ្មី.

ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ត្រូវមានមុខវិជ្ជា ដែលស្រង់ចេញពីវិស័យសិក្សាទាំងបួនផ្នែកដូចខាងក្រោម ៖

- សិល្បៈ និងមនុស្សសាស្ត្រ
- គណិតសាស្ត្រ វិទ្យាសាស្ត្រ និងកុំព្យូទ័រវិទ្យា
- វិទ្យាសាស្ត្រសង្គម
- ភាសាបរទេស

ចំនួនក្រេឌីតនៃមុខវិជ្ជាក្នុងវិស័យនីមួយៗ ត្រូវមានយ៉ាងតិច១០ភាគរយនៃពិន្ទុក្រេឌីតសរុប សម្រាប់វិញ្ញាបនបត្រថ្នាក់សិក្សាមូលដ្ឋាន។ មុខវិជ្ជាដែលនិស្សិតជ្រើសរើសនៅក្នុងឆ្នាំសិក្សាមូលដ្ឋាន ត្រូវស្របទៅនឹងផ្នែកជំនាញដែលនិស្សិតជ្រើសរើស ប៉ុន្តែនិស្សិតត្រូវតែសិក្សាមុខវិជ្ជាចាំបាច់ សម្រាប់ចូលសិក្សានៅថ្នាក់បរិញ្ញាបត្រ ។

មាត្រាពីរ.

មាត្រា ១១ថ្មីនៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៥ និងមាត្រា ១៦ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ត្រូវបានកែសម្រួលដូចខាងក្រោម ៖

មាត្រា ១១ថ្មីស្ទួន.

សមាជិក **គ.ទ.ក** ទាំងអស់ត្រូវជ្រើសតាំងឲបម្រើការងារមិនពេញម៉ោង និងទទួលប្រាក់ឧបត្ថម្ភតាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ។ ប្រាក់ឧបត្ថម្ភ របស់សមាជិក **គ.ទ.ក** ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ប្រធាន **គ.ទ.ក** ។

**គ.ទ.ក** មានអគ្គលេខាធិការដ្ឋានមួយចំណុះផ្ទាល់ទីស្តីការគណៈរដ្ឋមន្ត្រី ។ អគ្គលេខាធិការដ្ឋាន **គ.ទ.ក** ដឹកនាំដោយអគ្គលេខាធិការ០១រូប និងអមដោយអគ្គលេខាធិការរងមួយចំនួន ជាជំនួយការតាមចាំបាច់ ។ អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវតែតែងតាំងដោយព្រះរាជក្រឹត្យ ។ សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាននៃ **គ.ទ.ក** នឹងកំណត់ដោយអនុក្រឹត្យ ។

**គ.ទ.ក** មានបទបញ្ជាផ្ទៃក្នុង រូបសញ្ញា និងត្រាមួយ ដោយឡែករបស់ខ្លួន ។

មាត្រា បី.

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា បួន.

សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែននាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ប្រាំ.

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី